**LOWELL PUBLIC SCHOOLS**

Henry J. Mroz ការិយាល័យរដ្ឋបាលកណ្តាល

155 Merrimack Street

Lowell, MA 01852

ថ្ងៃទី 2 ខែវិច្ឆិកាឆ្នាំ 2020

ជូនចំពោះសិស្សានុសិស្ស បុគ្គលិក ក្រុមគ្រួសារ និងសហគមន៍ Lowell Public Schools ជាទីគោរពរាប់អាន

ឆ្នាំមុន មណ្ឌលរបស់យើងបានបោះជំហានយ៉ាងសំខាន់នៅក្នុងដំណើរការរៀបចំផែនការយុទ្ធសាស្ត្ររបស់យើង ដោយកំណត់ការប្តេជ្ញាជាមូលដ្ឋានគ្រឹះរបស់យើងចំពោះសមធម៌ថាជាកត្តាដ៏សំខាន់បំផុតសម្រាប់គ្រប់ផ្នែកនៃកិច្ចការងាររបស់យើង។ ទោះជាយ៉ាងណាក៏ដោយ យើងទាំងអស់គ្នាសុទ្ធតែដឹងថាការនិយាយតែគ្មានសកម្មភាពគឺមិនមានន័យអ្វីឡើយ។ យើងក៏ដឹងដែរថាក្នុងនាមជាថ្នាក់ដឹកនាំសាលារៀនសាធារណៈ យើងត្រូវតែទទួលខុសត្រូវមិនត្រឹមតែលើការពិនិត្យស្ថានភាពបុគ្គល និងការជាប់ពាក់ព័ន្ធនឹងការរើសអើងជាតិសាសន៍ប៉ុណ្ណោះទេ តែក៏ត្រូវត្រួតពិនិត្យការរើសអើងជាតិសាសន៍ដែលបានបង្កប់ក្នុងស្ថាប័នដែលបានបង្កលក្ខណៈឲ្យមានការរើសអើងជាតិសាសន៍ និងឯកសិទ្ធិដោយផ្ទាល់ ឬដោយប្រយោលនៅក្នុងគោលនយោបាយ និងការអនុវត្តរបស់មណ្ឌលមួយចំនួន។

ដោយយោងតាមការសន្យារបស់យើងដើម្បីទទួលខុសត្រូវចំពោះការដោះស្រាយការអសកម្ម ដែលបានធ្វើឲ្យប៉ះពាល់ដល់សហគមន៍សិក្សាចម្រុះរបស់យើងជាប្រវត្តិសាសន៍ យើងបានរៀបចំពិធីការថ្មីសម្រាប់ការរាយការណ៍ពីការប្រព្រឹត្តមិនត្រឹមត្រូវដោយសារការលម្អៀង (ឧ. ការរើសអើងការបៀតបៀន និងការរើសអើងជាតិសាសន៍)។ នេះគ្រាន់តែជាវិធីសាស្ត្រមួយឆ្ពោះទៅកាន់ការប្រយុទ្ធប្រឆាំងនឹងការអនុវត្តមិនស្មើភាពនៅក្នុងមណ្ឌលរបស់យើងប៉ុណ្ណោះ។

ក្នុងរយៈពេលពីរបីសប្តាហ៍ក្រោយនេះ យើងនឹងធ្វើការដើម្បីលើកកម្ពស់ការយល់ដឹងអំពីពិធីការរាយការណ៍ថ្មីនេះសម្រាប់បុគ្គលិក សិស្សានុសិស្ស និងក្រុមគ្រួសារដែលរួមមានស៊េរីនៃវគ្គបណ្តុះបណ្តាលអំពី ***ការប្រឆាំងការរើសអើងជាតិសាសន៍*** (*Anti-Racism*) ដែលបុគ្គលិក និងថ្នាក់ដឹកនាំនឹងចូលរួម។ វគ្គបណ្តុះបណ្តាលអំពីការប្រឆាំងការរើសអើងជាតិសាសន៍ទាំងនេះ នឹងចាប់ផ្តើមក្នុងខែវិច្ឆិកាសម្រាប់បុគ្គលិកទាំងអស់នៅទូទាំងមណ្ឌល។ ថ្នាក់ដឹកនាំសាលារៀន និងអ្នកគ្រប់គ្រងការិយាល័យកណ្តាលនឹងបន្តការបណ្តុះបណ្តាលប្រចាំខែពេញមួយឆ្នាំសិក្សា 2020-2021 ខណៈដែល

ក្រុមការងារមណ្ឌលរៀបចំគម្រោងឆ្ពោះទៅកាន់គម្រោងប្រឆាំងការរើសអើងជាតិសាសន៍ច្រើនឆ្នាំដើម្បីអនុវត្តនៅក្នុងមណ្ឌលទាំងមូលដោយចាប់ផ្តើមនៅឆ្នាំបន្ទាប់។

យើងទទួលស្គាល់ថា វានៅមានកិច្ចការជាច្រើនដែលត្រូវធ្វើដើម្បីធ្វើឱ្យប្រាកដថាសិស្សគ្រប់រូបនៅ Lowell - ដោយមិនគិតពីជាតិសាសន៍ ជាតិព័ន្ធ ឬស្ថានភាពសេដ្ឋកិច្ចសង្គម - មានសិទ្ធិស្មើគ្នាដើម្បីទទួលបានការអប់រំប្រកបដោយគុណភាព ដែលនឹងជួយឱ្យពួកគេសម្រេចបានសក្តានុពលដ៏អស្ចារ្យបំផុតរបស់ខ្លួន។ យើងប្រកាន់ខ្ជាប់នូវទំនួលខុសត្រូវ និងកាតព្វកិច្ចរបស់យើងចំពោះសិស្សានុសិស្សរបស់យើង និងសហគមន៍ LPS ដ៏ទូលំទូលាយដើម្បីបង្កើត និងរក្សាបាននូវបរិស្ថានដែលសិស្សានុសិស្សមានអារម្មណ៍ថាមានសុវត្ថិភាព មានការគោរព និងមានការជំរុញទឹកចិត្ត។ ទីបញ្ចប់ យើងបន្តប្តេជ្ញាខិតខំប្រឹងប្រែងប្រកបដោយឆន្ទៈ និងនិរន្តរភាពឆ្ពោះទៅកាន់ការពង្រឹងគោលនយោបាយ និងការអនុវត្តរបស់យើងទៅលើការគ្មានការរើសអើង ប្រឆាំងការបៀតបៀន និងប្រឆាំងការរើសអើងជាតិសាសន៍ដើម្បីបង្កើតបរិយាកាសសិក្សាដែលមានសុវត្ថិភាព និងការស្វាគមន៍។

សម្រាប់ព័ត៌មានបន្ថែមអំពីពិធីការថ្មីរបស់យើង សូមចូលទៅកាន់គេហទំព័រ LPS និងចុចលើថេប ***ការរើសអើង ការបៀតបៀន និងការរើសអើងជាតិសាសន៍ (Discrimination, Harassment, and Racism)*** ខាងក្រោម ***មណ្ឌលរបស់យើង*** (***Our District)*** ឬទាក់ទងទៅកាន់ការិយាល័យសមធម៌ និងការលើកកម្ពស់ (Office of Equity and Empowerment) តាមរយៈលេខ (978) 674-4326។ បន្ថែមលើនេះ សូមចំណាយពេលមួយភ្លែតដើម្បីមើល សាររីដេអូ ខ្លីមួយនេះដែលដោះស្រាយពីពិធីការថ្មីរបស់យើង និងការប្តេជ្ញាដើម្បីសម្រេចបាននូវសមធម៌របស់យើង។

ដោយក្តីស្មោះស្ម័គ្រ



Dr. Joel D. Boyd

នាយកសាលាប្រចាំមណ្ឌល